_ ផ្អែកតាមការចាំបាច់

**សំរេច**

**ប្រការ ១** : ប្រគល់ភារកិច្ចជូនឯកឧត្តម **សុខ អាន** សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ជា រដ្ឋមន្ត្រីស្តីទី ក្រសួងផែនការ ចាប់ពីថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ១៩៩៦ រហូតដល់ថ្ងៃឯកឧត្តម **ជា ចាន់តូ** ត្រឡប់មកពីបំពេញបេសកកម្មនៅឯបរទេសវិញ ។

**ប្រការ ២** : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការគ្រប់រដ្ឋលេខាធិការដ្ឋាន និង ឯកឧត្តម ដែលមានឈ្មោះក្នុងប្រការ ១ ត្រូវទទួលអនុវត្តសេចក្តីសំរេច ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

| | |
|---|---|
| **នាយករដ្ឋមន្ត្រីទី ១** | **នាយករដ្ឋមន្ត្រីទី ២** |
| **ព្រះហស្តលេខា និង ត្រា** | **ហត្ថលេខា និងត្រា** |
| **នរោត្តម រណឫទ្ធិ** | **ហ៊ុន សែន** |

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ២០ ខែ មីនា ឆ្នាំ ១៩៩៦

## សេចក្តីសំរេច លេខ : ០៧ សសរ

## ស្តីពីការបង្កើតក្រុមការងារសំរាប់ធ្វើការជាមួយ ក្រុមការងារ សមាគមន៍អ៊ឺរ៉ុបលើបញ្ហានាំចេញ សំលៀកបំពាក់ ទៅអ៊ឺរ៉ុប

* * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុវរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

**សំរេច**

**ប្រការ ១ :** បង្កើតក្រុមការងារមួយសំរាប់ធ្វើការជាមួយក្រុមការងារសហគមន៍អឺរ៉ុប លើបញ្ហានាំចេញសំលៀកបំពាក់ពីព្រះរាជាណាចក្រកម្ពុជាទៅសហគមន៍អឺរ៉ុប ក្នុងប្រព័ន្ធអនុគ្រោះពន្ធ GSP ដែលមានសមាសភាពដូចខាងក្រោម ÷

| | |
|---|---|
| ១–អនុរដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម | ជាប្រធាន |
| ២–តំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | សមាជិក |
| ៣–តំណាងក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ | សមាជិក |
| ៤–តំណាងក្រសួងផែនការ | សមាជិក |
| ៥–តំណាងក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល | សមាជិក |
| ៦–តំណាងគណៈកម្មាធិការជាតិវិនិយោគទុន | សមាជិក |
| ៧–ប្រធានទីចាត់ការគយ | សមាជិក |
| ៨–ប្រធាននាយកដ្ឋានពាណិជ្ជកម្មក្រៅប្រទេស | ស... |
| ៩–ប្រធានសមាគមរោងចក្រកាត់ដេរ | សមាជិ.. |
| ១០–មន្ត្រីក្រសួងពាណិជ្ជកម្ម | លេខាធិការ |

**ប្រការ ២ :** ក្រុមការងារនេះមានភារកិច្ច :

- រៀបចំបញ្ជីឯកសារ និងស្ថិតិចាំបាច់តាមក្រសួងនីមួយៗ ដើម្បីធ្វើការផ្ទៀងផ្ទាត់ជាមួយ ឯកសារដែលសហគមន៍អឺរ៉ុបបានទទួល ។

– ត្រៀមរបាយការណ៍ចាំបាច់ សំរាប់ពន្យល់តំណាងសហគមន៍អឺរ៉ុប និងការងារ របស់ក្រសួងនីមួយៗ ដែលពាក់ព័ន្ធដល់កានាំចេញទំនិញតាមប្រព័ន្ធអនុគ្រោះពន្ធ GSP ។

– ពិភាក្សារកវិធានការបំបាត់ការក្លែងបន្លំវិញ្ញាបនប័ត្រប្រភពដើមទំរង់ A ។

– ខិតខំពន្យល់អោយសហគមន៍អឺរ៉ុប យល់ពីការលំបាករបស់កម្ពុជា ដើម្បីអោយគេយោគ យល់ដល់កម្ពុជា លើការអនុវត្តមិនទាន់បានល្អ នូវបទបញ្ញត្តិនានាស្តីពីការនាំចេញតាម ប្រព័ន្ធ GSP ។

**ប្រការ ៣ :** សមាជិកទាំងអស់ត្រូវចូលរួមប្រជុំអោយបានទៀងទាត់តាមការអញ្ជើញរបស់ប្រធាន ។

**ប្រការ ៤ :** នៅពេលពិភាក្សា បើមានជួបការលំបាក ត្រូវសុំមតិណែនាំជាប្រចាំពីរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ក្នុងករណីចាំបាច់ត្រូវសុំមតិណែនាំពីសម្តេចនាយករដ្ឋមន្ត្រីទាំងពីរ ។

**ប្រការ ៥ :** សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួង សេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រី ក្រសួងផែនការ រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល អគ្គលេខាធិការវិនិយោគទុន រដ្ឋមន្ត្រីក្រសួងពាក់ព័ន្ធ និងសាម៉ីខ្លួន ដូចមានឈ្មោះក្នុងប្រការ ១ ត្រូវអនុវត្តសេចក្តីសំរេច នេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

| | |
|---|---|
| **នាយករដ្ឋមន្ត្រីទី ១** | **នាយករដ្ឋមន្ត្រីទី ២** |
| **ព្រះហស្តលេខា និង ត្រា** | **ហត្ថលេខា និងត្រា** |
| **នរោត្តម រណឫទ្ធិ** | **ហ៊ុន សែន** |

* * *